ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី

សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន

ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៥៣

**លេខ និងឈ្មោះសំណុំរឿង: ៦០/០៥ - អេវើរប្រ៊ីន អ៊ីភែរីល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់: ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងដោយផ្អែកតាមមាត្រា ៣១៣ នៃច្បាប់ស្តីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាលៈ

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អាន វីរៈ**

ប្រធានអាជ្ញាកណ្តាល (ជ្រើសរើសឡើងដោយអាជ្ញាកណ្តាលខាងលើ) : **តាំង ទ្រី**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន អេវើរប្រ៊ីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី**

អាសយដ្ឋាន: សួនឧស្សាហកម្មចុងយ៉ា ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥-១២) ២៥៦ ២៧៦

លេខទូរសារ: (៨៥៥-២៣) ៨៨១ ៦២៨

**តំណាងភាគីនិយោជកៈ**

| | |
|---|---|
| ១- លោក ប៊ុត ឫទ្ធី | ប្រធានធនធានមនុស្ស និងរដ្ឋបាល |
| ២- លោក ទ្រី មករា | ជំនួយការធនធានមនុស្ស និងរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធសហជីពយុវជនខ្មែរ និងសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន អេវើរប្រ៊ីន អ៊ីភែរីល

អាសយដ្ឋាន: ផ្ទះលេខ ៣៤ ឃ ផ្លូវលេខ២៦៥ សង្កាត់ ទឹកល្អក់ទី ៣ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥-១១) ៦២២ ៩៦៣

**តំណាងកម្មករនិយោជិត:**

១- លោក ម៉ែ វឌ្ឍនា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

២- លោក ហង់ សុរិយា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣- លោក ឈុន ភារម្យ អនុប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន អេវើរគ្រីន អ៊ីភែរីល

៤- លោក ម៉ៅ វិសាល លេខាធិការសហជីពយុវជនខ្មែរ

៥- លោក ឡុង សុផាត មន្ត្រីសំរបសំរួលសហព័ន្ធសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោម ជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទ :

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនជួយកាត់ប្រាក់ភាគទានឱ្យសហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន អេវើរគ្រីន អ៊ីភែរីល ខូអិលធីឌី ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា បើសហជីពយុវជនខ្មែរបានចុះបញ្ជិកាតាមត្រូវតាមច្បាប់ ហើយមានបញ្ជីឈ្មោះសមាជិកឯកភាពសុំឱ្យក្រុមហ៊ុនជួយកាត់ប្រាក់ភាគទានដែលមានលក្ខណៈសមស្របតាមច្បាប់ ទើបក្រុមហ៊ុនកាត់ជូនបាន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី ១២ ផ្នែកទី ២ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីការងារឆ្នាំ ១៩៩៧ ។ ប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នា

ឡើយ ហើយរបាយការណ៍ស្តីពីការមិនជាសះលេខ ៤៩៥ ក.ក.ប.វ/អ.ក/វ.ក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ (A) វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**

- ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ (វេលាម៉ោង ១៤:00 ដល់ម៉ោង ១៧:00)
- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥ (វេលាម៉ោង ១៤:00 ដល់ម៉ោង ១៦:៣0) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៥ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកកិច្ចប្រជុំមួយដើម្បីផ្សះផ្សាវិវាទរវាងកម្មករនិយោជិតនៃក្រុមហ៊ុន អេវើរគ្រីន អីភែរីល អិលធីឌី និងក្រុមហ៊ុន អេវើរគ្រីន អីភែរីល អិលធីឌី ។ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនជួយកាត់ប្រាក់ភាគទានសហជីពឱ្យសហជីពយុវជនខ្មែរប្រចាំរោងចក្រកាត់ដេរ អេវើរគ្រីន អីភែរីល (ខេមបូឌា) អិលធីឌី។ មន្ត្រីផ្សះផ្សាវិវាទបានខិតខំប្រឹងប្រែងក្នុងការផ្សះផ្សា ប៉ុន្តែភាគីវិវាទមិនបានសះជានឹងគ្នាលើចំណុចបញ្ហានៃការទាមទារនោះទេ ។ ដូច្នេះ ចំណុចបញ្ហាមិនសះជានេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ។ បន្ទាប់ពីបានទទួលសំណុំរឿង ភាគីទាំងអស់នៃវិវាទត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះហៅមកសវនាការនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោង ១៤:00 ។

ក្នុងសវនាការ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាបន្តលើចំណុចបញ្ហាមិនសះជាដែលបានបញ្ជូនមកដោះស្រាយ ប៉ុន្តែនៅតែមិនអាចផ្សះផ្សាបាន ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនការលើកទី២នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥ វេលាម៉ោង១៤:៤៥ នាទី ដើម្បីសាកសួររកអង្គហេតុបន្ថែម និង ភស្តុតាងសំរាប់សំណុំរឿង ហើយក៏បានបញ្ជាឱ្យភាគីបញ្ជូនភស្តុតាងទាក់ទងនឹងអំណះអំណាងរបស់ខ្លួនដែលបានលើកឡើងក្នុងសវនាការក្រោយពេលចប់សវនាការ ។

## ភស្តុតាង

**សាក្សី :** គ្មាន ។

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន :**

ក- ឯកសារបានទទួលពីភាគីនិយោជក :

- លក្ខន្តិកៈនៃក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី ចុះបញ្ជិកានៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥។
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មលេខ Inv-912/05P ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០៥ របស់ក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី។
- ឡិខិតលេខ ៤៥៣ ពណ.នតក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី។
- លិខិតលេខ ៤៨២/០៥ គ.វ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការការសំរេចជាគោលការណ៍លើសំណើវិនិយោគលើគំរោងបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់របស់ក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី។
- លិខិតលេខ ៤៨៣/០៥ គ.វ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការការសំរេចអនុញ្ញាតលើសំណើវិនិយោគលើបង្កើតក្រុមហ៊ុនវិនិយោគឈ្មោះអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី។
- វិញ្ញាបនប័ត្រចុះបញ្ជិកាលេខ ៧៩០ក.ក.ប.វ/វក.របស់សហជីពខ្មែរនៃរោងចក្រកាត់ដេរ អេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៥។
- លិខិតលេខ ១១៣៥ក.ក.ប.វ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៥ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការអនុញ្ញាតនូវការចុះបញ្ជិកានៃសហជីពខ្មែរនៃរោងចក្រ កាត់ដេរ អេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី។
- លិខិតបញ្ជាក់ការកាត់ប្រាក់បង់វិភាគទានសហជីពជាគំរូ ដែលមានចុះហត្ថលេខា និង ឬ មានផ្តិតស្នាមមេដៃ នា ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០៥(ចំនួន២ច្បាប់) របស់សហជីពខ្មែរប្រចាំរោងចក្រ អេវើរហ្គ្រីន អ៊ីភែរីល។
- ពាក្យសុំចូលជាសមាជិកជាគំរូ ដែលមានចុះហត្ថលេខា និង ឬ មានផ្តិតស្នាមមេដៃ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០៥(ចំនួន២ច្បាប់) របស់សហជីពខ្មែរប្រចាំរោងចក្រ អេវើរហ្គ្រីន អ៊ីភែរីល។
- ប្រវត្តិរូបសង្ខេបដែលមានចុះហត្ថលេខា និង/ឬ មានផ្តិតស្នាមមេដៃ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០៥ (ចំនួន២ច្បាប់) របស់សហជីពខ្មែរប្រចាំរោងចក្រ អេវើរហ្គ្រីន អ៊ីភែរីល។
- សំណុំពាក្យសុំចូលបំរើការងាររបស់កម្មការនីមួយរូប និងកិច្ចសន្យាការងារ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០០៣ រវាងក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល និងកម្មការនីមួយរូបនោះ ភ្ជាប់ជាមួយនូវឯកសារនៃការពន្យាកិច្ចសន្យារបស់កម្មការនីមួយរូបនោះ។

- តារាងបើកបៀវត្សសម្រាប់ខែមករា ឆ្នាំ២០០៥ របស់ក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល ដែលបាន បង្ហាញនូវថ្ងៃចូលធ្វើការផ្សេងៗគ្នាតាំងពីក្នុងខែមករា ឆ្នាំ២០០៣ រហូតដល់ ខែមករា ឆ្នាំ ២០០៥។

ខ. ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

- វិញ្ញាបនប័ត្រចុះបញ្ជិកាលេខ ៥៧៣សកបយ.អក. ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០០៤ របស់ សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនឡុងក្លឺរី។
- លិខិតលេខ ២៨០សកបយ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង និតិសម្បទា ស្តីពីការអនុញ្ញាតនូវការចុះបញ្ជិកានៃ សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនឡុងក្លឺរី។
- លិខិតជូនដំណឹងលេខ ៤៤៥ស.ស.យ.ខ. ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការបោះឆ្នោត ជ្រើសរើសប្រតិភូសហជីពយុវជនខ្មែរប្រចាំរោងចក្រកាត់ដេរអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌីដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី៦ ខែសីហា ឆ្នាំ ២០០៥។
- បង្កាន់ដៃទទួលសំណុំរឿងចេញដោយនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០០៥។
- ពាក្យសុំកាត់វិភាគទាន ជូនសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនរោងចក្រកាត់ដេរអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី ដែលមានចុះហត្ថលេខា និង ឬ មានផ្តិតស្នាមមេដៃ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០៥(ចំនួន១ ច្បាប់)។
- កាតការងាររបស់កម្មករម្នាក់នៃក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី៥ ខែមិនា ឆ្នាំ ២០០៥(ចំនួន១ ច្បាប់)។
- កាតការងាររបស់កម្មករម្នាក់នៃក្រុមហ៊ុនក្រុមហ៊ុនឡុងក្លឺរី ចុះថ្ងៃទី៨ ខែមិនា ឆ្នាំ ២០០៣ (ចំនួន១ ច្បាប់)។
- លិខិតលេខ ៣១៤ស.ស.យ.ខ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ ២០០៥ស្តីពីសំណើសុំលោកនាយករោងចក្រ អេវើរហ្គ្រីន អ៊ីភែរីល ធ្វើការកាត់ប្រាក់ឈ្នួលពីសមាជិកក្នុងមួយនាក់ចំនួន ១០០០ រៀលដើម្បីបង់ ភាគទានសហជីព ដោយមានភ្ជាប់មកជាមួយនូវបញ្ជីរាយនាមសមាជិក-សមាជិការសហជីពយុវជន ខ្មែរប្រចាំក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល ដែលស្ម័គ្រចិត្តឱ្យកាត់ប្រាក់ភាគទាន។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល ខូអិលធីឌី លេខ ៤៩៥ ក.ក.ប.វ/អ.ក/វ.ក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥
- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល :

- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការ លេខ ៣៣៥ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥
- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ ៣៣៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ។

## អង្គហេតុ

ក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល មានទីតាំងនៅផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានជួលកម្មករនិយោជិត ១១៦១ នាក់ ។

- ក្រោយពីបានពិនិត្យរបាយកាណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថាៈ**

- ម្ចាស់ក្រុមហ៊ុនអេវើរហ្គ្រីន អ៊ីភែរីល មុនពេលដំណើរការរោងចក្រកាត់ដេរ អេវើរហ្គ្រីន អ៊ីភែរីលនេះ ធ្លាប់ដំណើរការរោងចក្រកាត់ដេរ ឡុងក្លូរី ដែលមានទីតាំងនៅ ខណ្ឌឫស្សីកែវ តាំងពីឆ្នាំ២០០៣ ដែលមានលក្ខណៈជាក្រុមហ៊ុនម៉ៅការបន្ត ។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនឡុងក្លូរីបានទទួលការចុះបញ្ជិកានាថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៤ ជាមួយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនឡុងក្លូរី បានទទួលប្រាក់ភាគទានពីសមាជិករបស់ខ្លួន ជាប្រចាំខែ ដោយក្រុមហ៊ុនឡុងក្លូរី បានកាត់ពីប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិកសហជីព ស្របតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងច្បាប់ស្តីពីការងារ និង ប្រកាសដែលពាក់ព័ន្ធ ។

- សហជីពបានអះអាងថា ក្នុងការស្នើសុំកាត់ប្រាក់ភាគទានសហជីពនេះ ខ្លួនបានដាក់តែប្រវត្តិរូបសង្ខេប របស់សមាជិកខ្លួនតែប៉ុណ្ណោះ ។ ចំពោះករណីនេះ ខាងក្រុមហ៊ុនមិនមានការអះអាងណាមួយឡើយ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលយកអំណះអំណាងរបស់ភាគីកម្មករនិយោជិតជាការពិត ។
- ក្រុមហ៊ុន អេវើរហ្គ្រីន អឺភែរីល ត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីពាណិជ្ជកម្មនាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០៥ ដែលរោងចក្រមានទីតាំងស្ថិតនៅអាស័យដ្ឋាន សួនឧស្សាហកម្ម ចុងយ៉ា ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។
- នៅ ថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៥ ក្រុមហ៊ុន អេវើរហ្គ្រីន អឺភែរីល បានទទួលបញ្ជិកាត្រឹមត្រូវក្នុងការដំណើរមុខជំនួញរបស់ខ្លួន ប៉ុន្តែក្រុមហ៊ុនបានចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួនតាំងពីខែមករា ឆ្នាំ២០០៥ ។
- នៅពេលអេវើរហ្គ្រីន អឺភែរីល ចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួន កម្មករនិយោជិតមួយចំនួនធំដែលបាន កំពុងបំរើការឱ្យរោងចក្រឡុងក្លឺរី បានព្រមព្រៀងទៅធ្វើការនៅរោងចក្រ អេវើរហ្គ្រីន អឺភែរីល ។ ក្រុមហ៊ុនបានទទួលស្គាល់ និងរក្សាអតីតភាពការងារពីរោងចក្រឡុងក្លឺរី ព្រមទាំងផ្តល់ប្រាក់ឧបត្ថមចំនួន ៥ ដុល្លាអាមេរិក ដល់កម្មករទាំងនោះដែលព្រមទៅធ្វើការនៅក្រុមហ៊ុនអេវើរហ្គ្រីន អឺភែរីល ។
- សហជីពយុវជនខ្មែរបានដាក់ពាក្យស្នើសុំចុះបញ្ជិកា ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ ហើយបើគិតមកទល់នឹងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៥ ត្រូវគិតថាមានចំនួន២ខែគត់ តែមុទល់នឹងថ្ងៃសវនាការលើកទី២នេះ ក្រសួងមិនទាន់បានផ្តល់វិញ្ញាប័ត្រចុះបញ្ជិកាថ្មីជូនសហជីពនៅឡើយទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា សហជីពនេះបានចុះបញ្ជិកាត្រឹមត្រូវ ដោយហេតុថា រយៈពេលសុំចុះបញ្ជិកានេះលើសពីពីរខែដែលច្បាប់កំណត់ ។
- សហជីពយុវជនខ្មែរបានដាក់ជូនក្រុមហ៊ុន អេវើរហ្គ្រីន អឺភែរីល នូវពាក្យសុំកាត់ប្រាក់ភាគទានរបស់សមាជិកខ្លួន ដោយនៅលើកទី១ ក្នុងពាក្យសុំនោះសរសេរឈ្មោះក្រុមហ៊ុនមិនទាន់ត្រឹមត្រូវល្អដែលត្រូវបានក្រុមហ៊ុនបដិសេធ និង សូមឱ្យសហជីពធ្វើការកែតំរូវឈ្មោះក្រុមហ៊ុនឱ្យបានត្រឹមត្រូវឡើងទើបក្រុមហ៊ុនធ្វើការកាត់ប្រាក់ភាគទានសហជីពជូន ព្រោះថាបើត្រឹមតែអេវើរហ្គ្រីន នោះអាចច្រឡំជាមួយនឹងរោងចក្រកាត់ដេរមួយទៀតដែលមានឈ្មោះថា អេវើរហ្គ្រីន ដែរ។
- សហជីពបានកែតំរូវឈ្មោះ លើពាក្យសុំទាំងនោះ ដោយបិតក្រដាសបន្ថែមលើពាក្យសុំចាស់ ដោយយោងតាមយោបល់របស់មន្ត្រីរដ្ឋបាលក្រុមហ៊ុន ។ ប៉ុន្តែក្រោយមកក្រុមហ៊ុននៅតែបដិសេធមិនកាត់ប្រាក់ភាគទានឱ្យសហជីពដដែល ដោយតំរូវឱ្យសហជីពដាក់ពាក្យសុំដែលមានឈ្មោះត្រឹមត្រូវ

របស់ក្រុមហ៊ុន អេវើរប្រ៊ិន អ៊ីភែរីល (អិលធីឌី) និង ព័ត៌មានមួយចំនួនទៀតដើម្បីសំរួលដល់គណនេយ្យករក្នុងការកាត់ប្រាក់ឈ្នួលនេះ ដូចជាអត្តលេខ ផ្នែក ក្រុម របស់កម្មករ ជាដើម ។

- សហជីពយុវជនខ្មែរបានអះអាងថានៅពេលទើបប្តូរមកធ្វើការនៅរោងចក្រ អេវើរប្រ៊ិន អ៊ីភែរីល នោះ ក្រុមហ៊ុនបានកាត់ប្រាក់ភាគទានឱ្យសហជីពយុវជនខ្មែរនៅខែមករា ។ ក្រុមហ៊ុនបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល និង សហជីពនូវបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែមករា ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មិនមានការកាត់ប្រាក់ភាគទានហសជីពពីប្រាក់ឈ្នួលកម្មករនិយោជិតដូចការអះអាងរបស់សហជីពឡើយ ម៉្យាងវិញទៀត សហជីពក៏មិនបានបញ្ជូននូវឯកសារភស្តុតាងបញ្ជាក់ថា សហជីពយុវជនខ្មែរបានទទួលប្រាក់ភាគទានសហជីពនៅខែមករាដែរ ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថាពាក្យសុំកាត់ប្រាក់វិភាគទានចាស់ប្រើប្រាស់ឈ្មោះសហជីពយុវជនខ្មែរប្រចាំរោងចក្រអេវើរប្រ៊ិន អ៊ីភែរីល មានបិតពីក្រដាសបន្ថែមលើពាក្យសុំនោះដោយសរសេរពាក្យ "អេវើរប្រ៊ិន អ៊ីភែរីល" ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា សំណុំឯកសារតាមទម្រង់ថ្មីមួយរបស់សហជីពខ្មែរប្រចាំរោងចក្រ អេវើរប្រ៊ិន អ៊ីភែរីលដែល ពាក់ព័ន្ធ ទៅនឹងការស្នើសុំការកាត់ប្រាក់វិភាគទានថាមានលក្ខណៈគ្រប់គ្រាន់តាមតំរូវការរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនក៏យល់ព្រមទទួលយកនូវទម្រង់បែបបទសុំកាត់ប្រាក់ភាគទានសហជីពថ្មីនេះដែរ នៅក្នុងសវនការអាជ្ញាកណ្តាល ។

## ហេតុផលនៃសេចក្តីសម្រេច

ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន កាត់ប្រាក់ភាគទានសហជីពឱ្យសហជីពយុវជនខ្មែរប្រចាំរោងចក្រ អេវើរប្រ៊ិន អ៊ីភែរីល ។ ភាគីនិយោជកបានយល់ព្រមកាត់ប្រាក់ភាគទានសហជីពឱ្យសហជីពយុវជនខ្មែរនៅពេលដែលបានទទួលពាក្យសុំកាត់ជាលាយលក្ខអក្សរត្រឹមត្រូវពីសមាជិកសហជីព ។ និយោជកបានតំរូវឱ្យសហជីពផ្តល់នូវឯកសារព័ត៌មានដូចជា បញ្ជីឈ្មោះសមាជិកសហជីព ឈ្មោះកម្មករនិយោជិត អត្តលេខ ក្រុម ផ្នែក និង ហត្ថលេខា ឬស្នាមមេដៃ ។

មាត្រា១២៩ កថាខណ្ឌទី២ នៃច្បាប់ការងារចែងថា: "ប៉ុន្តែកម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ប្រាក់ភាគទានសហជីពដែលខ្លួនជាសមាជិក ។ ការអនុញ្ញាតនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង អាចបដិសេធវិញបានគ្រប់ពេលវេលា ។"

កថាខណ្ឌចុងក្រោយនៃប្រការ ៥ នៃប្រកាសលេខ៣០៥ ចែងថា: " កម្មករនិយោជិតទាំងអស់ដែលជាសមាជិកសហជីព អាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១៥ថ្ងៃមុន ដើម្បីឱ្យនិយោជកកាត់ប្រាក់ឈ្នួល

របស់ខ្លួន ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ស្របតាមមាត្រា១២៩នៃច្បាប់ការងារ ហើយនិយោជក ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវតាមសំណើនេះ ។ ...”

យោងតាមអង្គហេតុ សហជីពយុវជនខ្មែរ បានដាក់ពាក្យសុំកាត់ប្រាក់ភាគទានរបស់សមាជិកសហជីព ទៅក្រុមហ៊ុន ។ មានពាក្យសុំខ្លះមានបិតក្រដាសបន្ថែម ដោយសរសេរថា "អេវើរប្រ៊្លិន អ៊ីភែរីល" លើក្រដាស ពាក្យសុំដែលមានឈ្មោះក្រុមហ៊ុនមិនពេញលេញ"អេវើរប្រ៊្លិន"។ និយោជកបានអះអាងថាក្រុមហ៊ុននឹងកាត់ប្រាក់ ភាគទានសហជីពឱ្យ កាលណាមានពាក្យសុំជាលាយអក្សរត្រឹមត្រូវ និង បដិសេធមិនទទួលយកពាក្យសុំទាំងឡាយ ដែលមានបិតក្រដាសបន្ថែម ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យសុំកាត់ប្រាក់ភាគទានសហជីពនោះរបស់កម្មករនិយោជិត ម្នាក់ៗ មិនគួរមានការកោសលុប ឬ បិតក្រដាសបន្ថែមនោះទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅក្នុង ករណីនេះ ការភាន់ច្រឡំដែលកើតឡើងដោយសារការផ្តល់យោបល់របស់មន្ត្រីក្រុមហ៊ុននោះគឺ ដើម្បីសំរួលដល់ការ កែតំរូវលើឈ្មោះមិនពេញលេញរបស់ក្រុមហ៊ុនដោយបិតក្រដាសបន្ថែម ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ ឃើញថា គោលបំណងនៃការតំរូវឱ្យមានការអនុញ្ញាតជាលាយលក្ខណអក្សរក្នុងការកាត់ប្រាក់ភាគទានសហជីពនេះ គឺដើម្បីការពារកម្មករនិយោជិតម្នាក់ៗ ពីការកាត់ប្រាក់ឈ្នួលរបស់គាត់ផ្ទុយពីឆន្ទៈរបស់គាត់ និង ដើម្បីការពារ ក្រុមហ៊ុនពីកំហុសឆ្គងក្នុងការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ។ ទាំងនេះគឺជាផលប្រយោជន៍នៃការព្រួយ បារម្ភ ដើម្បីធានាថាឯកសារសុំកាត់ប្រាក់ឈ្នួលទាំងអស់ត្រឹមត្រូវ និង បង្ហាញពីឆន្ទៈ និងគោលបំណងរបស់កម្មករ និយោជិតម្នាក់ៗ ។

ចំពោះព័ត៌មានដែលភាគីនិយោជកតំរូវឱ្យមាននៅក្នុងពាក្យសុំជាលាយលក្ខណអក្សរនោះ ច្បាប់ការងារ មិនមានចែងថាតើ ទម្រង់បែបបទជាលាយលក្ខណអក្សរសំរាប់ការសុំកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួល កម្មករនិយោជិតនោះ គួរមានព័ត៌មានណាខ្លះនោះទេ ។ លើសពីទៅទៀតគ្មានបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ ប្រកាសកំណត់អំពីចំនុចលំអិតនៃពាក្យ សុំកាត់ប្រាក់វិភាគទានដែលនឹងត្រូវដាក់ជូនភាគីនិយោជកដើម្បីឱ្យកាត់ជូន សហជីពដែរ ។

នៅក្នុងសវនការ សហជីពបានបង្ហាញក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោជកនូវពាក្យសុំកាត់ប្រាក់ ភាគទាន សហជីពថ្មីមួយដែលមានព័ត៌មានដូចជា ឈ្មោះកម្មករនិយោជិត ផ្នែក ក្រុម អត្តលេខ ហត្ថលេខា ឬ ស្នាមមេដៃ របស់សាមីជន ព្រមទាំងហត្ថលេខារបស់តំណាងសហជីពយុវជនខ្មែរប្រចាំរោងចក្រ អេវើរប្រ៊្លិន អ៊ីភែរីល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ព័ត៌មានដែលមានក្នុងទម្រង់បែបបទសុំកាត់ប្រាក់ភាគទាននេះ មានព័ត៌មានគ្រប់គ្រាន់សំរាប់ក្រុមហ៊ុន ជាពិសេសបង្កលក្ខណៈងាយស្រួលដល់គណនេយ្យករក្នុងការកាត់ប្រាក់ភាគ

ទានសហជីព ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ។ ម៉្យាងវិញទៀត ភាគីនិយោជកបានយល់ព្រមទទួលយកនូវទម្រង់បែបបទរបស់សហជីពនេះដែរ ។

លើសពីនេះ នៅក្នុងសំណុំរឿងនេះ តំណាងភាគីនិយោជកបានស្នើឱ្យសហជីពផ្តល់ឱ្យក្រុមហ៊ុននូវបញ្ជីឈ្មោះ សមាជិកសហជីពទាំងអស់ ដើម្បីបញ្ជាក់ថាកម្មករនិយោជិតដែលអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់គាត់នោះពិតជាសមាជិកសហជីពមែន ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់ការងារមិនតំរូវឱ្យសហជីពផ្តល់បញ្ជីរាយឈ្មោះសមាជិក-សមាជិការទាំងអស់ ដោយរួមទាំងកម្មករនិយោជិតដែលមិនបានយល់ព្រមអោយកាត់ប្រាក់វិភាគទាននោះឡើយ ។ ប្រសិនបើ និយោជកមានហេតុផលសមស្របនិងជាក់ស្តែង ទាក់ទងនឹងភាពស្របច្បាប់នៃលិខិតអនុញ្ញាតជាលាយលក្ខអក្សររបស់កម្មករនិយោជិតនោះ និយោជកអាចតំរូវឱ្យសហជីពបញ្ជាក់ថាតើកម្មករនិយោជិតដែលបានយល់ព្រមឱ្យកាត់ប្រាក់ភាគទានពីប្រាក់ឈ្នួលខ្លួននោះពិតជាសមាជិករបស់សហជីពមែនឬទេ ដោយឱ្យសហជីពផ្តល់នូវបញ្ជីឈ្មោះសមាជិកសហជីពដែលអនុញ្ញាតឱ្យកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់ពួកគេ។ នេះគឺដើម្បីឱ្យនិយោជកធានាបានថាកម្មករនិយោជិតនោះជាសមាជិកសហជីពដូចដែលបានតំរូវដោយប្រការ៥ នៃប្រកាសលេខ ៣០៥ ។

នៅក្នុងសំណុំរឿងលេខ ៦២/០៤ - អ៊ី ស៊ីន ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា:

*"ប្រសិនបើសហជីពមានបំណងឱ្យនិយោជកកាត់ប្រាក់វិភាគទានសហជីពពីប្រាក់ឈ្នួលរបស់កម្មករសហជីពត្រូវប្រគល់ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ និង អាចយកជាការបាន ដូចជាបញ្ជីឈ្មោះ ដែលមានហត្ថលេខា ឬស្នាមមេដៃរបស់កម្មករសាមុី និងលិខិតផ្សេងៗទៀត ដែលមានលក្ខណៈរួមគ្នាក្តី ឬមានលក្ខណៈជាបុគ្គលក្តី ដែលយល់ព្រមនិងអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនសំរាប់បង់វិភាគទានសហជីព ។ នៅពេលទទួលបានឯកសារនេះ និយោជកត្រូវកាត់ប្រាក់វិភាគទាននេះ ហើយប្រគល់ឱ្យសហជីពរៀងរាល់ខែ ។ ជាបន្ថែមទៀត សហជីពត្រូវជូនដំនឹងជាលាយលក្ខណ៍អក្សរឱ្យនិយោជក អំពីការផ្លាស់ប្តូរការយល់ព្រមឱ្យនិយោជកកាត់ប្រាក់ភាគទានពីប្រាក់ឈ្នួលរបស់កម្មករ ។"*

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា ដើម្បីអាចឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានជូនសហជីពបានសហជីពត្រូវដាក់នូវជូនបញ្ជីឈ្មោះសមាជិករបស់ខ្លួនដែលអនុវញ្ញាតឱ្យកាត់ប្រាក់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់ពួកគេ និង ទម្រង់បែបបទសុំកាត់ប្រាក់ភាគទានរបស់សមាជិកម្នាក់ៗ តាមទម្រង់ថ្មី ដែលបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ភាគីនិយោជកនៅក្នុងសវនាការ ។ ភាគីនិយោជកត្រូវកាត់ប្រាក់ភាគទានជូនសហជីពបន្ទាប់ពីទទួលការស្នើសុំ និង ទម្រង់បែបបទស្នើសុំជាលាយលក្ខណ៍អក្សរ និង ប្រគល់ប្រាក់ភាគទានដែលកាត់ទាំងអស់ជូនសហជីពជារៀងរាល់ខែ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សំរេចចេញសេចក្តីបង្គាប់ដូចតទៅ :

## បង្គាប់ និង សម្រេច

១- បង្គាប់ភាគីនិយោជក ក្រុមហ៊ុន អេវើរគ្រីន អឺភែរឹល (ខេមបូឌា) អិលធីឌី កាត់ប្រាក់ភាគទានសហជីពជូនសហជីពយុវជនខ្មែរប្រចាំរោងចក្រ អេវើរគ្រីន អឺភែរឹល តាមការស្នើសុំរបស់សមាជិកសហជីព បន្ទាប់ពីបានទទួលពាក្យសុំជាលាយលក្ខណ៍ត្រឹមត្រូវ ។

២- បង្គាប់សហជីពយុវជនខ្មែរប្រចាំរោងចក្រ អេវើរគ្រីន អឺភែរឹល ជូនដំណឹងទៅក្រុមហ៊ុនអំពីការស្នើសុំកាត់ប្រាក់ភាគទានសហជីពដោយភ្ជាប់ជូនជាមួយនូវបញ្ជីរាយឈ្មោះកម្មករនិយោជិតដែលជាសមាជិកសហជីព និង ពាក្យសុំកាត់ប្រាក់ភាគទានជាលាយលក្ខណអក្សររបស់សមាជិកម្នាក់ៗ ដែលបានស្ម័គ្រចិត្តឱ្យកាត់ប្រាក់ភាគទានពីប្រាក់ឈ្នួល ។ ពាក្យសុំកាត់ប្រាក់ភាគទានសហជីពត្រូវមានព័ត៌មានលំអិតដូចជា ឈ្មោះកម្មករនិយោជិត អត្តលេខ មុខងារ ក្រុម ផ្នែក និង ហត្ថលេខា ឬស្នាមមេដៃសាមីជន។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ចងកាតព្វកិច្ច ។**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ពីព្រោះភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ចងកាតព្វកិច្ច នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ : **យូ សួនធី**

ហត្ថលេខា:-------------------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា:-------------------------------------------------------

ប្រធានអាជ្ញាកណ្តាល :

ឈ្មោះ : **តាំង ទ្រី**

ហត្ថលេខា:-------------------------------------------------------